# សំណួរដែលអ្នកអាចសួរទៅកាន់គ្រូពេទ្យរបស់កូនអ្នក អំពីថ្នាំបង្ការជំងឺ COVID-19

## សំណួរទូទៅ

ខ្ញុំមានការព្រួយបារម្ភអំពីថ្នាំបង្ការជំងឺ COVID-19 សម្រាប់កូនរបស់ខ្ញុំ។ តើពួកយើងអាចពិគ្រោះគ្នាអំពីថ្នាំបង្ការទាំងនោះបានដែរឬទេ?

ខ្ញុំចាប់អារម្មណ៍ចង់ស្វែងយល់បន្ថែមអំពីថ្នាំបង្ការ COVID-19 សម្រាប់កូនរបស់ខ្ញុំ។ តើអ្នកអាចប្រាប់ខ្ញុំអំពីវាបានដែរឬទេ?

តើអ្នកអាចប្រាប់ខ្ញុំអំពីដំណើរការនៃការអនុម័តឱ្យប្រើប្រាស់ថ្នាំបង្ការសម្រាប់កុមារបានដែរឬទេ?

តើមានកុមារចំនួនប៉ុន្មាននាក់ហើយដែលបានទទួលចាក់ថ្នាំបង្ការនេះ?

ដំណើរការនេះមើលទៅហាក់ដូចជាលឿន តើអ្នកអាចប្រាប់ខ្ញុំអំពីរបៀបដែលដំណើរការនៃថ្នាំបង្ការនេះមានចំណុចខុសគ្នាពីថ្នាំបង្ការផ្សេងទៀតយ៉ាងដូចម្តេចខ្លះ?

តើដំណើរការដើម្បីទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ថ្នាំបង្ការសម្រាប់កុមារមានអ្វីខ្លះ?

តើកូនរបស់អ្នកបានទទួលចាក់ថ្នាំបង្ការដែរឬទេ?

តើមានកុមារកំពុងឆ្លងជំងឺ COVID-19 ដែរឬទេ? តើមានកុមារកំពុងធ្លាក់ខ្លួនឈឺដោយសារជំងឺ COVID-19 ដែរឬទេ? តើការឈឺនេះមានសភាពយ៉ាងដូចម្តេចទៅ?

ខ្ញុំបានឮ(លឺ)ថាជំងឺCOVID-19មិនប៉ះពាល់ដល់កុមារទេ។តើនេះជាការពិតដែរឬទេ?តើមានមូលហេតុអ្វីខ្លះដែលត្រូវយកកូនរបស់ខ្ញុំទៅទទួលចាក់ថ្នាំបង្ការនាពេលនេះបើប្រៀបធៀបទៅនឹងការរង់ចាំសិន?

ខ្ញុំមានការព្រួយបារម្ភអំពីបញ្ហារលាកសាច់ដុំបេះដូង (myocarditis)។ តើអ្នកអាចពិគ្រោះគ្នាជាមួយខ្ញុំអំពីស្ថានភាពបេះដូងនេះ និងហានិភ័យចំពោះស្ថានភាពនេះដែលពាក់ព័ន្ធទៅនឹងការឆ្លង COVID-19 និងថ្នាំបង្ការបានដែរឬទេ?

តើកូនរបស់ខ្ញុំនឹងមានបញ្ហារលាកសាច់ដុំបេះដូងដែរឬទេប្រសិនបើពួកគេទទួលចាក់ថ្នាំបង្ការ? តើខ្ញុំត្រូវសង្កេតរកមើលសញ្ញាអ្វីទៅ?

ប្រសិនបើ កូនរបស់ខ្ញុំធ្លាប់កើតជំងឺ COVID-19 រួចហើយ តើពួកគេនៅតែចាំបាច់ត្រូវចាក់ថ្នាំបង្ការដែរឬទេ? តើខ្ញុំត្រូវរង់ចាំរយៈពេលប៉ុន្មាន មុនពេលទទួលចាក់ថ្នាំបង្ការ?

តើថ្នាំបង្ការប្រភេទ mRNA មានដំណើរការយ៉ាងដូចម្តេច?

---

## អំពីដូសនៃថ្នាំបង្ការ

តើបរិមាណដូសសម្រាប់មនុស្សពេញវ័យនិងបរិមាណដូសសម្រាប់កុមារមានភាពខុសគ្នាយ៉ាងណា?

តើបរិមាណដូសសម្រាប់កុមារដែលមានអាយុចាប់ពី 5ទៅ11ឆ្នាំនិងបរិមាណដូសសម្រាប់កុមារដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ មានភាពខុសគ្នាយ៉ាងណា?

តើមានគម្លាតចំនួនប៉ុន្មានថ្ងៃ រវាងដូសទាំងនេះ?

តើកូនរបស់ខ្ញុំត្រូវការចាក់ចំនួន2ដូសហើយត្រូវចាក់ដូសជំរុញថែមទៀតមែនឬទេ? តើយើងចង់ទទួលចាក់ ឬត្រូវការចាក់ដូសជំរុញនៅពេលណា?

## កង្វល់ផ្នែកវេជ្ជសាស្ត្រ

កូនរបស់ខ្ញុំមាន _____ តើថ្នាំបង្ការនេះនឹងជះឥទ្ធិពលដល់ពួកគេយ៉ាងដូចម្តេច?

កូនរបស់ខ្ញុំប្រើប្រាស់ថ្នាំ _____ ។ តើថ្នាំបង្ការជះឥទ្ធិពលដល់ថ្នាំនេះដែរឬទេ?

ខ្ញុំបានលឺអំពី _____ តើអ្នកអាចពិគ្រោះគ្នាជាមួយខ្ញុំអំពីវាបានដែរឬទេ?

តើខ្ញុំគួរពិចារណាអំពីគម្លាតដែលយូរជាងមុនរវាងដូសសម្រាប់កូនជំទង់របស់ខ្ញុំដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅដែរឬទេ?

---

## ផលប៉ះពាល់រយៈពេលខ្លី

តើខ្ញុំគួររំពឹងអ្វីខ្លះអំពីថ្នាំបង្ការក្នុងរយៈពេលខ្លី?

តើផលប៉ះពាល់នៃការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ជាទូទៅមានអ្វីខ្លះ?

តើខ្ញុំគួរសង្កេតរកមើលសញ្ញាអ្វីខ្លះ បន្ទាប់ពីទទួលចាក់ដូសទីមួយ?

តើខ្ញុំគួរសង្កេតរកមើលសញ្ញាអ្វីខ្លះ បន្ទាប់ពីទទួលចាក់ដូសទីពីរ?

---

## ផលប៉ះពាល់រយៈពេលវែង

ខ្ញុំមានការព្រួយបារម្ភអំពីផលប៉ះពាល់រយៈពេលវែងនៃថ្នាំបង្ការចំពោះកូនរបស់ខ្ញុំ។ តើអ្នកអាចពិគ្រោះគ្នាជាមួយខ្ញុំ អំពីផលប៉ះពាល់ទាំងនេះបានដែរឬទេ?

តើអ្នកអាចពិគ្រោះគ្នាជាមួយខ្ញុំ អំពីផលប៉ះពាល់រយៈពេលវែងនៃថ្នាំបង្ការដែលធ្លាប់បានដឹង បានដែរឬទេ?

តើផលប៉ះពាល់រយៈពេលវែងពីការឆ្លងជំងឺ COVID-19 សម្រាប់កុមារមានអ្វីខ្លះ?

---

## របៀបនិយាយជាមួយកូនរបស់អ្នក

ខ្ញុំមិនសូវដឹងច្បាស់ថាត្រូវនិយាយជាមួយកូនរបស់ខ្ញុំ អំពីការចាក់ថ្នាំបង្ការជំងឺ COVID-19 យ៉ាងដូចម្តេចខ្លះទេ។ តើអ្នកមានយោបល់យ៉ាងណាដែរ?

កូនរបស់ខ្ញុំខ្លាចជំងឺ COVID-19។ តើអ្នកមានយោបល់ អំពីរបៀបនិយាយជាមួយពួកគេអំពីជំងឺ COVID-19 យ៉ាងណាដែរ? ចុះអំពីថ្នាំបង្ការ?

កូនរបស់ខ្ញុំខ្លាចការចាក់ថ្នាំតើខ្ញុំអាចត្រៀមខ្លួនកូនរបស់ខ្ញុំឱ្យទទួលចាក់ថ្នាំបង្ការបានយ៉ាងដូចម្តេច?

---

## ការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 រួមជាមួយថ្នាំបង្ការផ្សេងទៀត

តើវាមានសុវត្ថិភាពក្នុងការទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 រួមជាមួយនឹងថ្នាំបង្ការតាមកាលកំណត់ផ្សេងទៀតសម្រាប់កូនរបស់ខ្ញុំ ដែរឬទេ?

តើមានការណែនាំឱ្យទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលតំណាលគ្នាជាមួយនឹងថ្នាំបង្ការតាមកាលកំណត់ផ្សេងទៀត ដែរឬទេ?